# របាយការណ៍

## សិក្ខាសាលាថ្នាក់តំបន់ ស្តីពីការពិនិត្យមើលលទ្ធផល និងការពង្រឹងគុណភាពជាបន្ត ក្នុងការស្វែងរកករណី ផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥

Regional Workshop to Review the Results and Continuous Quality Improvement of HIV Case finding, Prevention, and Care and Treatment Services towards the national targets of 95:95:95

ថ្ងៃព្រហស្បត្តិ៍ ១៤រោច ខែអស្សុជ ដល់ ថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ត្រូវនឹងថ្ងៃទី៣១ ខែតុលា ដល់ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០២៤ ខេត្តតាកែវ



**រៀបចំដោយ**

**ឧបត្ថម្ភដោយ**

US CDC Cambodia

# របាយការណ៍

## សិក្ខាសាលាថ្នាក់តំបន់ ស្តីពីការពិនិត្យមើលលទ្ធផល និងការពង្រឹងគុណភាពជាបន្ត ក្នុងការស្វែងរកករណីផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥

Regional Workshop to Review the Results and Continuous Quality Improvement of HIV Case finding, Prevention, and Care and Treatment Services towards the national targets of 95:95:95

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្រោមជំនួយថវិកាពី US CDC បាន រៀបចំ សិក្ខាសាលាថ្នាក់តំបន់ ស្តីពីការពិនិត្យមើលលទ្ធផល និងការពង្រឹងគុណភាពជាបន្ត ក្នុងការ ស្វែងរកករណីផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ នាថ្ងៃព្រហស្បតិ៍ ១៤រោច ខែអស្សុជ ដល់ថ្ងៃ សុក្រ ១ កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ដល់ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០២៤ ក្រោមការចង្អុលបង្ហាញ និងដឹកនាំដ៏ខ្ពង់ខ្ពស់របស់លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា ប្រធាន មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានចាត់តាំង លោកវេជ្ជ. ង៉ូវ ប៉ូរ៉ា អនុប្រធានមជ្ឈមណ្ឌលជាតិ ដឹកនាំ សិក្ខាសាលានេះ ដែលប្រព្រឹត្តទៅនៅមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តតាកែវ។

### ១. គោលបំណង៖

**គោលបំណងរួម៖**

ដើម្បីធានានូវលទ្ធផល និងសមាមាត្រខ្ពស់នៃល្បាក់ទាំងមូលតាំងពីការរកឃើញអ្នកផ្ទុកមេរោគអេដស៍ រហូតដល់ចុះឈ្មោះនិងទទួលសេវាថែទាំនិងព្យាបាលប្រកបដោយគុណភាព

**គោលបំណងជាក់លាក់៖**

- **ពិនិត្យលទ្ធផលសម្រេចបាននៃសូចនាករសំខាន់ៗទាក់ទងនឹង៩៥ទី១៖**
  - សូចនាករសំខាន់ៗ ៧ របស់ ការធ្វើតេស្តមេរោគអេដស៍ (HIV testing) និងការធ្វើតេស្តករណីឆ្លងថ្មី
  - សូចនាករសំខាន់ៗ របស់សេវាតាមរក និងធ្វើតេស្តដៃគូ របស់អ្នកផ្ទុកមេរោគអេដស៍ (PNTT)
  - សូចនាករសំខាន់ៗ របស់សេវាផ្តល់ថ្នាំបង្ការមុនប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍
- **ពិនិត្យលទ្ធផលសម្រេចបាននៃសូចនាករសំខាន់ៗទាក់ទងនឹង៩៥ទី២ និងទី៣៖**
  - % អ្នកជំងឺART ដែលបានស្លាប់

- % អ្នកជំងឺARTខកណាត់ ≤28ថ្ងៃ ដែលបានដាក់ឱ្យទទួលសេវាវិញ
- % អ្នកជំងឺបាត់មុខ >28ថ្ងៃ ដែលបានដាក់ឱ្យទទួលសេវាវិញ
- % ការមកពិនិត្យតាមការណាត់, មុនថ្ងៃណាត់, យឺតនៅថ្នាំបម្រុង, យឺតអស់ថ្នាំបម្រុង
- % អ្នកជំងឺផ្តើមARTថ្មីនៅក្នុងត្រីមាសដែលចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ក្នុងថ្ងៃតែមួយនឹងថ្ងៃធ្វើរោគវិនិច្ឆ័យថាមានផ្ទុកមេរោគអេដស៍
- % អ្នកជំងឺបាន និងកំពុងទទួលឱសថនិងការណាត់ជួប ≥3 months
- % អ្នកជំងឺផ្តើមARTថ្មីដំបូង ដោយឱសថTLD
- % អ្នកជំងឺសរុបបានទទួល ឱសថ TLD មកទល់នឹងចុងត្រីមាសរាយការណ៍
- % អ្នកជំងឺដែលសមស្របធ្វើVL តេស្តនៅក្នុងត្រីមាស បានធ្វើVLតេស្ត
- % លទ្ធផលVLតេស្តបានត្រឡប់មកដល់គ្លីនិកវិញ ក្នុងអំឡុងពេល១០ថ្ងៃ
- % អ្នកជំងឺសកម្មកំពុងប្រើART បានធ្វើតេស្តVL ក្នុងអំឡុងពេល១២ខែកន្លងមក
- % អ្នកជំងឺសកម្មកំពុងប្រើART មានVLបង្ក្រាប (WHO VLS.3 pro.-level denominator)
- % អ្នកជំងឺសកម្មកំពុងប្រើART មានVLបង្ក្រាប (WHO VLS.3 pop.-level denominator)
- % អ្នកជំងឺដែលបានបញ្ចប់TPT នៅចុងត្រីមាសរាយការណ៍
- % អ្នកជំងឺបន្តបិតនៅក្នុងសេវាARTរបស់យើង (Retention rate)

- **កំណត់បញ្ហាអាទិភាព និងមូលហេតុដែលទាក់ទងនឹងលទ្ធផលនៃសូចនាករទាប**
- **រៀបចំផែនការសកម្មភាពដើម្បីកែលម្អ**

## ២. របៀបវារៈនៃសិក្ខាសាលា

| ម៉ោង | មាតិកា | គ្រូសម្របសម្រួល |
|---|---|---|
| | ៣១ ខែតុលា ឆ្នាំ ២០២៤ | |
| ០៧:៣០-០៨:០០ | ការចុះឈ្មោះ | មជ្ឈមណ្ឌលជាតិ |
| ០៨:០០-០៨:៤៥ | • មតិចំណាប់អារម្មណ៍ របស់ លោកវេជ្ជបណ្ឌិត Chan Sodara តំណាង US-CDC Cambodia<br>• មតិសំណេះសំណាល របស់ លោកវេជ្ជបណ្ឌិត ង៉ូវ បូរ៉ា អនុប្រធាន មជ្ឈមណ្ឌលជាតិ<br>• មតិសំណេះសំណាល និងប្រកាសបើកវគ្គសិក្ខាសាលា របស់ លោកឱសថ-ការីឧត្តម ផាន វ៉ាន់ ប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តតាកែវ | មជ្ឈមណ្ឌលជាតិ |
| ០៨:៤៥-០៩:០០ | ការរំពឹងទុក និង វិន័យវគ្គសិក្ខាសាលា | មជ្ឈមណ្ឌលជាតិ |
| ០៩:០០-០៩:១៥ | សម្រាកអាហារសម្រន់ | |
| ០៩:១៥-០៩:៤៥ | HIV Prevention, Care and Treatment Programs in Cambodia | វេជ្ជ. ង៉ូវ បូរ៉ា<br>វេជ្ជ. ចាន់ សូដារា |
| ០៩:៤៥-១០:១៥ | ពិនិត្យលទ្ធផលនៃការអនុវត្តការងារបង្ការថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី៣ ឆ្នាំ ២០២៤ នៅគ្រប់សេវាទូទាំងប្រទេស៖ 1st 95<br>(សំនួរ & ចម្លើយ) | វេជ្ជ. ហេង សុផាត<br>វេជ្ជ. គី សុវឌ្ឍនា |
| ១០:១៥-១១:០០ | ពិនិត្យលទ្ធផលនៃការអនុវត្តការងារបង្ការថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី៣ ឆ្នាំ ២០២៤ នៅគ្រប់សេវាទូទាំងប្រទេស៖ 2nd & 3rd 95 | វេជ្ជ. ប្រាក់ ណារុំ |

| | | |
|---|---|---|
| | (សំនួរ & ចម្លើយ) | វេជ្ជ. ធិល សារីម |
| ១១:០០-១១:៣០ | បង្ហាញពី បច្ចុប្បន្នភាពគ្លីនិកស្តីពី MPOX (សំនួរ & ចម្លើយ) | វេជ្ជ. ញ៉ែម ចន្ថា |
| ១១:៣០-១២:០០<br><br>ខេត្តកំពង់ស្ពឺ | ពិនិត្យលទ្ធផលនៃការអនុវត្ត ការធ្វើតេស្តមេរោគអេដស៍និង ការងារុករកករណីផ្ទុកមេរោគអេដស៍ និង ការបង្ការ ត្រឹមត្រីមាសទី៣ ឆ្នាំ ២០២៤ (1st 95)<br>ពិនិត្យលទ្ធផលនៃការអនុវត្តការងារថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី៣ ឆ្នាំ ២០២៤ នៅមន្ទីរពេទ្យបង្អែកឧដុង្គ (2nd & 3rd 95)<br>(សំនួរ & ចម្លើយ) | អ្នកតំណាងមន្ទីរសុខាភិបាលខេត្ត<br>អ្នកតំណាងសេវាART នៃមន្ទីរពេទ្យ |
| ១២:០០-១៣:៣០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១៣:៣០-១៥:០០<br>ខេត្ត មណ្ឌលគីរី<br>ខេត្តពោធិ៍សាត់<br>ខេត្តព្រៃវែង | ពិនិត្យលទ្ធផលនៃការអនុវត្ត ការធ្វើតេស្តមេរោគអេដស៍និង ការងារុករកករណីផ្ទុកមេរោគអេដស៍ និង ការបង្ការ ត្រឹមត្រីមាសទី៣ ឆ្នាំ ២០២៤ (1st 95)<br>ពិនិត្យលទ្ធផលនៃការអនុវត្តការងារថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី៣ ឆ្នាំ ២០២៤ នៅមន្ទីរពេទ្យបង្អែកឧដុង្គ (2nd & 3rd 95)<br>(សំនួរ & ចម្លើយ) | អ្នកតំណាងមន្ទីរសុខាភិបាលខេត្ត<br>អ្នកតំណាងសេវាART នៃមន្ទីរពេទ្យ |
| ១៥:០០-១៥:១៥ | សម្រាកអាហារសម្រន់ | |
| ១៥:១៥-១៦:៤៥<br>ស្វាយរៀង<br>កណ្តាល<br>ត្បូងឃ្មុំ | ពិនិត្យលទ្ធផលនៃការអនុវត្ត ការធ្វើតេស្តមេរោគអេដស៍និង ការងារុករកករណីផ្ទុកមេរោគអេដស៍ និង ការបង្ការ ត្រឹមត្រីមាសទី៣ ឆ្នាំ ២០២៤ (1st 95)<br>ពិនិត្យលទ្ធផលនៃការអនុវត្តការងារថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី៣ ឆ្នាំ ២០២៤ នៅមន្ទីរពេទ្យបង្អែកឧដុង្គ (2nd & 3rd 95)<br>(សំនួរ & ចម្លើយ) | អ្នកតំណាងមន្ទីរសុខាភិបាលខេត្ត<br>អ្នកតំណាងសេវាART នៃមន្ទីរពេទ្យ |
| ១៦:៤៥-១៧:០០ | សង្ខេបថ្ងៃទី០១ និងសំណួរ & ចម្លើយ | គ្រូសម្របសម្រួលទាំងអស់ |
| **ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០២៤** | | |
| ០៨:០០-០៩:៣០<br>ខេត្តកែប<br>ខេត្តរតនគីរី | ពិនិត្យលទ្ធផលនៃការអនុវត្ត ការធ្វើតេស្តមេរោគអេដស៍និង ការងារុករកករណីផ្ទុកមេរោគអេដស៍ និង ការបង្ការ ត្រឹមត្រីមាសទី៣ ឆ្នាំ ២០២៤ (1st 95)<br>ពិនិត្យលទ្ធផលនៃការអនុវត្តការងារថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី៣ ឆ្នាំ ២០២៤ នៅមន្ទីរពេទ្យបង្អែកឧដុង្គ (2nd & 3rd 95)<br>(សំនួរ & ចម្លើយ) | អ្នកតំណាងមន្ទីរសុខាភិបាលខេត្ត<br>អ្នកតំណាងសេវាART នៃមន្ទីរពេទ្យ |
| ០៩:៣០-១០:៣០ | ពិភាក្សា៖<br>- កំណត់បញ្ហាអាទិភាព និងមូលហេតុដែលទាក់ទងនឹងលទ្ធផលទាប<br>- រៀបចំផែនការសកម្មភាពដើម្បីកែលម្អ<br>(សេវាART នីមួយៗ ពិនិត្យលទ្ធផលដែលនៅមានកំរិត និង ពិភាក្សាជ្រើសរើសបញ្ហាជាអាទិភាព សម្រាប់ដោះស្រាយ និងធ្វើផែនការកែលម្អសេវា អោយកាន់តែមានប្រសិទ្ធិភាពខ្ពស់) | អ្នកសម្របសម្រួលទាំងអស់ |
| ១០:៣០-១០:៤៥ | សម្រាកអាហារសម្រន់ | |
| ១០:៤៥-១២:០០ | បង្ហាញ លទ្ធផលកិច្ចពិភាក្សា និង ផែនការកែលម្អសេវា (សេវាART នីមួយៗ មានរយៈពេល ១៥នាទី ក្នុងការបង្ហាញ និង ៥នាទីសម្រាប់សំនួរ-ចម្លើយ) | អ្នកសម្របសម្រួលទាំងអស់ |
| ១២:០០-១៣:៣០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១៣:៣០-១៥:៣០ | សរុបលទ្ធផល នៃកិច្ចពិភាក្សា។ តំណាងខេត្តនីមួយៗបង្ហាញផែនការសកម្មភាពដើម្បីកែលម្អ | អ្នកសម្របសម្រួលទាំងអស់ |
| ១៥:៣០-១៥:៤៥ | សម្រាកអាហារសម្រន់ | |
| ១៥:៤៥-១៦:១៥ | សេចក្តីសន្និដ្ឋាន និង ធ្វើការវាយតម្លៃវគ្គសិក្ខាសាលា | អ្នកសម្របសម្រួលទាំងអស់ |
| ១៦:១៥-១៦:៤៥ | បិទវគ្គសិក្ខាសាលា | អ្នកសម្របសម្រួល |

សិក្ខាសាលាថ្នាក់តំបន់ ស្តីពីការពិនិត្យមើលលទ្ធផល និងការពង្រឹងគុណភាពជាបន្ត ក្នុងការស្វែងរកករណីផ្ទុកមេរោគអេដស៍ និងការផ្តល់សេវាបង្ការ និងថែទាំ ព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ ក្រោមការឧបត្ថម្ភថវិកាដោយ US CDS Cambodia នៅមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តតាកែវ។



គណៈធិបតី ក្នុងកិច្ចបើកវគ្គសិក្ខាសាលា រួមមាន៖

1. លោកវេជ្ជ. ចាន់ សូដារា តំណាង មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក គម្រោង US CDC Cambodia
2. លោកវេជ្ជ. ង៉ូវ បូរ៉ា អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ
3. លោកឱសថការីឧត្តម ផាន់ វ៉ាន់ ប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តតាកែវ

អ្នកចូលរួម ក្នុងវគ្គសិក្ខាសាលា រួមមាន ប្រធានកម្មវិធីអេដស៍ ប្រធានផ្នែកថែទាំព្យាបាលជំងឺអេដស៍ តាមមន្ទីរសុខាភិបាលខេត្ត មន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែក មកពីខេត្ត/រាជធានី ចំនួន ១០ រួមមាន ខេត្តកំពង់ស្ពឺ កែប ព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ មណ្ឌលគិរី រតនៈគីរី កណ្តាល ពោធិ៍សាត់ និងរាជធានីភ្នំពេញ និង តំណាងស្ថាប័នម្ចាស់ជំនួយ អង្គការពាក់ព័ន្ធ នានា សរុបចំនួន ៤៥ នាក់។ បន្ទាប់ពីកិច្ចស្វាគមន៍ មតិចំណាប់អារម្មណ៍ និងប្រកាសបើកវគ្គរបស់គណៈធិបតីរួចមក ក្រុមការងារបានអញ្ជើញគណៈធិបតី និងសិក្ខាកាមទាំងអស់ចូលរួម និងថតរូបអនុស្សាវរីយ៍។ បន្ទាប់មក ក្រុមការងារបានបង្ហាញពីគោលបំណង របៀបវារៈ និងការបង្ហាញរបស់តំណាងខេត្តនីមួយៗ ទៅតាមកម្មវិធីដែលបានគ្រោងទុក។




## លទ្ធផលរំពឹងទុក

ក្នុងរយៈពេល ២ថ្ងៃ នៃវគ្គសិក្ខាសាលា លទ្ធផលរំពឹងទុក រួមមាន៖

- តំណាងសេវាថែទាំព្យាបាល និង ប្រធានកម្មវិធីអេដស៍ បានបង្ហាញពី លទ្ធផល និងសូចនាករសំខាន់ៗ របស់គោលដៅ 95-95-95 ទាំង ៣ និង បញ្ហាកត្តាប្រឈម នៅតាមខេត្តនីមួយៗ។
- ពិភាក្សា និងស្វែងរកដំណោះ ចំពោះបញ្ហាជាក់លាក់។
- ជ្រើសរើសសូចនាករ ដែលត្រូវពង្រឹងបន្ត។
- ធ្វើផែនការកែលម្អ សកម្មភាពបង្ការ និងថែទាំព្យាបាល មេរោគអេដស៍ ដើម្បីសម្រេចបានគោលដៅ
- អនុវត្តផ្តល់សេវាបង្ការ ថែទាំព្យាបាល មានប្រសិទ្ធិភាព ដើម្បីសម្រេចបានគោលដៅ 95-95-95